# តម្លៃនៃជីវិត

*ដកស្រង់ចេញពីសៀវភៅ*

*ជីវប្រវត្ត ព្រះបវរសត្ថា ពេជ្រ-តុល*

**"អជ្ជេវ កិច្ចំ អាតប្បំ កោ ជញ្ញាមរណំ សុវេ**

**ន ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនា"។**

*"សេចក្ដីព្យាយាមជាគ្រឿងកម្ចាត់បង់នូវសៅហ្មង គឺបុគ្គលត្រូវធ្វើក្នុងថ្ងៃនេះឯង អ្នកណាអាចដឹងថា សេចក្ដីស្លាប់នឹងមកក្នុងថ្ងៃស្អែក ព្រោះថា ការបណ្ដោះបណ្ដោ អំពីមច្ចុ ដែលមានសេនាទាហានច្រើន មិនមានសោះឡើយ"។*

*ពុទ្ធភាសិតនេះ បានក្រើនរំឭកស្មារតីនៃមនុស្សឲ្យដឹងថា ជីវិត ជាធម្មជាតិមានចលនា ដែលមិនមានអ្នកណាអាចដឹងបាន ជីវិតនឹងមាននៅឬនឹងអស់ទៅ ស្រេចហើយតែចលនានៃធម្មជាតិ ព្រោះជីវិតត្រូវព័ទ្ធជុំជិតអំពីកងទាហាននៃសេចក្ដីស្លាប់ ដែលជាកងទ័ពមានសេចក្ដីខ្លាំងពូកែខាងធ្វើការវាយលុកចូលបន្ទាយជីវិត ដោយពុំមានសត្វលោកណាម្នាក់ អាចធ្វើការប្រយុទ្ធតទល់បានឡើយ។*

*បំណងពុទ្ធភាសិតនេះ ចង់ប្រាប់យើងឲ្យដឹងថា វេលាមានតម្លៃ អ្នកត្រូវការសេចក្ដីសុខ-ចម្រើន ត្រូវការដឹកនាំជីវិតឲ្យរួចផុតចាកសេចក្ដីទុក្ខ គប្បីប្រញាប់ប្រ-ញាល់ធ្វើការឲ្យបានគ្រប់ពេល ទោះជាពេលល្អក្ដី ពេលអាក្រក់ក្ដី ព្រោះវេលាដើរទៅជីវិតក៏ដើរទៅព្រមជាមួយវេលា។ គប្បីប្រយ័ត្នឬសំចៃវេលា ដែលជារបស់មានតម្លៃបំផុត មានតម្លៃនៅលើរបស់ទាំងអស់សម្រាប់ខ្លួនអ្នកជាបុគ្គលធ្វើការ។ វេលាមាន*

ជីវិតជាអាហារ តែជីវិតមនុស្ស ក៏មានវេលាជាទ្រព្យ បុគ្គលម្នាក់ៗ មិនគប្បីឲ្យវេលាប្រព្រឹត្តកន្លងទៅដោយពុំបានធ្វើការយកចំណេញអំពីវេលា។ អ្នកមានសេចក្តីព្យាយាមធ្វើការងារ ទោះជាស្លាប់ក្នុងវ័យក្មេងក៏មិនជាមនុស្សអភ័ព្វប៉ុន្មានទេ តែអ្នកខ្ជិលច្រអូសមិនធ្វើការងារ ទោះជារស់នៅដល់វ័យចាស់ ក៏មិនមានភ័ព្វវាសនាអ្វីដែរ។ ជីវិតរបស់មនុស្ស បើស្តីដោយការរស់នៅយូរឆាប់ មិនឃើញមានអ្វីជាសំខាន់ជាងគ្នាទេ តែជីវិតអ្នកធ្វើការជាជីវិតថ្លៃថ្នូរបំផុត។

បុគ្គលកាលបើដឹងថា ជីវិតរបស់ខ្លួន ត្រូវឡោមព័ទ្ធដោយកងទ័ពនៃធម្មជាតិហើយ ត្រូវក្រោកឡើងធ្វើការវាយប្រយុទ្ធទម្លាយកងទ័ពនោះ ដោយប្រើកុសលាវុធគ្រប់បែបយ៉ាង។ នៅក្នុងលោកនេះ មិនមានសង្គ្រាមឯណាអាចធ្វើឲ្យមនុស្សមានសេចក្តីភ័យខ្លាចជាងសង្គ្រាមជីវិត ដែលគេកំពុងធ្វើសព្វថ្ងៃនេះទេ។ បញ្ហារស់បានចោទឲ្យមនុស្សនាំគ្នាដោះស្រាយ តែទោះជាមនុស្សនាំគ្នាខំដោះស្រាយយ៉ាងណាក៏ដោយ ចំណោទនេះក៏នៅតែក្នុងសភាពទាល់ច្រក មិនមានទ្វារចេញ ដោយមកពីមនុស្សទាំងអស់មិនមែនត្រូវការត្រឹមតែរស់ប៉ុណ្ណោះទេ គឺត្រូវការចង់ធ្វើឲ្យសេចក្តីរស់នៅរបស់ខ្លួន បានប្រសើរជាងសេចក្តីរស់នៅរបស់អ្នកដទៃ គឺចំណង់ (តណ្ហា) នៃមនុស្សនេះហើយ ដែលនាំឲ្យកើតសង្គ្រាមជីវិត។ ក្នុងកាលណាមនុស្សមិនទាន់ទម្លាយបោលនូវចំណង់ គឺតណ្ហានេះទេ ក្នុងពេលនោះ សង្គ្រាមជីវិតនឹងមិនបាត់ពីពិភពលោកឡើយ។

ព្រះសម្មាសម្ពុទ្ធទ្រង់យល់ឃើញយ៉ាងនេះ ទើបត្រាស់សម្តែងថា “សេចក្តីព្យាយាមជាគ្រឿងដុតបំផ្លាញកិលេស គឺបុគ្គលត្រូវធ្វើក្នុងថ្ងៃនេះ...” កិលេសក្នុងទីនេះដោយកតណ្ហាដែលជាហេតុនៃទុក្ខ ត្រូវនឹងពុទ្ធភាសិតមួយកន្លែងទៀតថា “តណ្ហា-

ក្ខយោ សព្វទុក្ខំ ជិនាតិ ការអស់តណ្ហា ឈ្នះទុក្ខទាំងអស់"។

"អនិមិត្តមនញ្ញាតំ មច្ចានំ ឥធ ជីវិតំ

កសិរញ្ច បរិត្តញ្ច តញ្ច ទុក្ខេន សំយុតំ"។

"ជីវិតរបស់មនុស្សទាំងឡាយក្នុងលោកនេះ រកកំណត់គ្មាន មិនមានអ្នកណាមួយអាចដឹងបានថា ជីវិតនេះលំបាកផង តិចផង ប្រកបដោយសេចក្តីទុក្ខច្រើនផង"។

ពុទ្ធភាសិតនេះ មានន័យដូចពុទ្ធភាសិតខាងដើមនោះដែរ គឺមានបំណងចង់ឲ្យមនុស្សស្គាល់បញ្ហាជីវិត ឲ្យនាំគ្នាខំប្រឹងដោះស្រាយចំណោទរបស់ជីវិតតាមវិធីនៃសច្ចធម៌ ដើម្បីធ្វើសេចក្តីទុក្ខឲ្យរលាយបាត់ទៅម្តងបន្តិចៗ ក្នុងទីបំផុតនឹងបានដល់ត្រើយដែលមិនមានសេចក្តីទុក្ខ គឺព្រះនិព្វានន៎ុះឯង។

<u>ប្រមូលភាសិត</u>

"វេលាជាសត្រូវរបស់ជីវិត

តែការងារដែលកើតឡើងអំពីវេលា

ជាកល្យាណមិត្តរបស់ជីវិត។

ព្រះពុទ្ធទ្រង់ប្រោសប្រាណអ្នកធ្វើការ

ទេវតារក្សាគ្រប់គ្រងអ្នកតស៊ូ"។

នៅវត្តលង្កា ថ្ងៃ៧១២ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥០៤

ត្រូវនឹងថ្ងៃទី៦ ខែមករា គ.ស.១៩៦២

ភិក្ខុ ទៀវ-ជុំ

ស្រាវជ្រាវដោយៈ ជាច់ សុតឹម